# សៀវភៅមគ្គុទ្ទេសក៍

## ប្រព័ន្ធស្នើសុំអាជ្ញាបណ្ណទេសចរណ៍
## តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន

Powered by CamDX

# មាតិកា

១. ព័ត៌មានទូទៅ

២. សំណើសុំអាជ្ញាបណ្ណទេសចរណ៍

# ១. ព័ត៌មានទូទៅ



# ហេតុអ្វីត្រូវស្នើសុំអាជ្ញាបណ្ណ?

គ្រប់ក្រុមហ៊ុន-សហគ្រាសទាំងឡាយ ដែលធ្វើប្រតិបត្តិការអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានកាតព្វកិច្ចចុះបញ្ជីអាជីវកម្ម ដែលប្រៀបបាននឹងការចុះសំបុត្រកំណើតសម្រាប់ក្រុមហ៊ុន-សហគ្រាស ។ បន្ថែមលើនេះ, ក្រុមហ៊ុន-សហគ្រាសមួយចំនួន ក៏មានកាតព្វកិច្ចស្នើសុំអាជ្ញាបណ្ណផ្សេងៗទៅតាមប្រភេទនៃសកម្មភាពអាជីវកម្ម ដែលប្រៀបបាននឹងការទទួលស្គាល់ជាផ្លូវការពីសំណាក់រាជរដ្ឋាភិបាល នូវគុណវុឌ្ឍិរបស់ក្រុមហ៊ុន-សហគ្រាស ។

# ហេតុអ្វីត្រូវស្នើសុំអាជ្ញាបណ្ណ?

បន្ថែមលើអត្ថប្រយោជន៍នៃការចុះបញ្ជីអាជីវកម្ម ដែលបានរៀបរាប់ក្នុងសៀវភៅមគ្គុទ្ទេសក៍ ស្តីពីដំណើរការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, ការស្នើសុំអាជ្ញាបណ្ណផ្តល់នូវអត្ថប្រយោជន៍ ដូចខាងក្រោម៖

- ផ្តល់ទំនុកចិត្ត និងភាពទាក់ទាញដល់អតិថិជន ដោយអាជ្ញាបណ្ណបង្ហាញពីគុណវុឌ្ឍិ ដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាល
- ចំណេញពេលវេលា និងកាត់បន្ថយបន្ទុកចំណាយផ្សេងៗ
- ចូលរួមគោរពច្បាប់ និង ត្រូវបានការពារដោយច្បាប់
- ចូលរួមបង់ពន្ធ និងបង់ថ្លៃអាជ្ញាបណ្ណ និងកម្រៃសេវាផ្សេងៗជូនរាជរដ្ឋាភិបាល
- រួចផុតពីការចោទប្រកាន់ថារកស៊ីជាមួយជនខិលខូច ឬចូលរួមទប់ស្កាត់អំពើល្មើសផ្សេងៗនៅក្នុងវិស័យ

# ហេតុអ្វីត្រូវស្នើសុំអាជ្ញាបណ្ណ?

- អាជ្ញាធរ មានការងាយស្រួល ក្នុងការគ្រប់គ្រង តាមដាន សកម្មភាពផ្សេងៗ ជាពិសេស សន្តិសុខ
- ផ្តល់សេវាខិតជិតដល់មូលដ្ឋាន និងកាន់តែងាយស្រួលក្រៅពីប្រព័ន្ធធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ
- មានទំនុកចិត្តពីអតិថិជន និងងាយស្រួលកៀគរ និងពង្រីកទីផ្សារ
- មានសិទ្ធិប្រកបអាជីវកម្មស្របច្បាប់ ដោយមានអាជ្ញាបណ្ណអាជីវកម្ម
- សម្រួលដល់ការស្នើសុំអត្ថប្រយោជន៍ផ្សេងៗពីរាជរដ្ឋាភិបាល ដូចជាការផ្តល់ការលើកទឹកចិត្តផ្នែកសារពើពន្ធ និង/ឬ កម្ចីដែលមានការប្រាក់ទាប ជាដើម។

# ទិដ្ឋភាពទូទៅនៃការស្នើសុំអាជ្ញាបណ្ណ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

## ប្រភេទអាជ្ញាបណ្ណ

- អាជ្ញាបណ្ណសណ្ឋាគារ៖ សម្រាប់អាជីវកម្មសណ្ឋាគារ ឬសណ្ឋាគារអាផាតមិន ឬសណ្ឋាគារស្វ៊ីត ឬសណ្ឋាគាររីសត ឬប៊ឹងហ្គាឡូ ឬម៉ូតែល ឬកន្លែងបោះជំរុំ ទាំងមានចំណាត់ថ្នាក់ ឬគ្មានចំណាត់ថ្នាក់ ដែលតម្លៃអាជ្ញាបណ្ណត្រូវបានកំណត់ជាកញ្ចប់ ។
- អាជ្ញាបណ្ណសេវាស្នាក់នៅទេសចរណ៍៖ សម្រាប់អាជីវកម្មសម្រាប់ការស្នាក់នៅ ដែលតម្លៃអាជ្ញាបណ្ណត្រូវបានកំណត់ទៅតាមចំនួនបន្ទប់ ។
- អាជ្ញាបណ្ណភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍៖ សម្រាប់អាជីវកម្មដែលរៀបចំឡើងដើម្បីបម្រើសេវាកម្មម្ហូបអាហារ និងភេសជ្ជៈសម្រាប់ភ្ញៀវ ដែលសំដៅដល់បុគ្គលដែលធ្វើដំណើរដើម្បីសម្រាក លំហែ កម្សាន្ត ធុរកិច្ច និងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត ក្នុងនាមជាអ្នកទេសចរ ឬជាអ្នកធ្វើដំណើរ ។
- អាជ្ញាបណ្ណភ្នាក់ងារទេសចរណ៍ និងការីទេសចរណ៍៖ សម្រាប់អាជីវកម្មរៀបចំដោយផ្ទាល់ ឬលក់សេវាកម្មទេសចរណ៍ ដូចជា សំបុត្រមធ្យោបាយធ្វើដំណើរ សេវាកម្មស្នាក់នៅទេសចរណ៍ និង សេវាកម្មទេសចរណ៍ផ្សេងៗទៀត ។

# និន្នាការទូទៅនៃការស្នើសុំអាជ្ញាបណ្ណ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

**សម្គាល់៖** ក្រសួងទេសចរណ៍ មានផ្តល់អាជ្ញាបណ្ណជាច្រើនប្រភេទផ្សេងទៀត ដែលត្រូវធ្វើការស្នើសុំតាមនីតិវិធីកន្លងមកជាធរមាន។ រាជរដ្ឋាភិបាលនឹងរៀបចំជាបន្តបន្ទាប់នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការស្នើសុំអាជ្ញាបណ្ណបន្ថែម នាពេលអនាគត។

# ឯកសារតម្រូវ

រាល់ឯកសារភ្ជាប់ទាំងអស់ត្រូវស្ថិតក្នុងទម្រង់ PDF រីឯរូបថតត្រូវស្ថិតក្នុងទម្រង់ JPG ឬ jpeg ដែលស្កេនពីច្បាប់ដើម ហើយមានគុណភាពល្អ។

សូមបញ្ជាក់ថា ប្រសិនបើអ្នកមិនផ្តល់ឯកសារ ឬព័ត៌មានគ្រប់គ្រាន់ ពិតប្រាកដ និងច្បាស់លាស់ ក្នុងពេលដែលអ្នកដាក់ពាក្យស្នើសុំអាហារូបករណ៍ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់យើង, សំណើសុំអាហារូបករណ៍របស់អ្នកនឹងត្រូវពន្យារពេល ឬអាចប្រឈមនឹងការបដិសេធ។ ក្នុងករណីនេះ រាល់ការចំណាយដែលបានធ្វើឡើងលើប្រព័ន្ធនេះ នឹងមិនមានការធានាចំពោះការប្រគល់ប្រាក់ជូនវិញនោះទេ។

# ឯកសារតម្រូវ

**១. ឯកសារតម្រូវសម្រាប់ អាជ្ញាបណ្ណសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍៖**

- លិខិតអនុញ្ញាតសាងសង់ ឬ ជួសជុលចេញដោយក្រសួង ឬមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- កិច្ចសន្យាអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងច្បាប់នានារបស់រដ្ឋ
- លិខិតបញ្ជាក់ពីប្រព័ន្ធគ្រប់គ្រងអគ្គីភ័យ និងប្រព័ន្ធការពារសន្តិសុខ សុវត្ថិភាព ចេញដោយក្រសួងមហាផ្ទៃ ឬ ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំ
- វិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
- រូបថតរបស់អ្នកគ្រប់គ្រង ( ៤x៦ )

# ឯកសារតម្រូវ

២. ឯកសារតម្រូវសម្រាប់អាជ្ញាបណ្ណភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍៖

- ➢ លិខិតអនុញ្ញាតដាក់ទីតាំងប្រកបអាជីវកម្មចេញដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ➢ កិច្ចសន្យាអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងច្បាប់នានារបស់រដ្ឋ
- ➢ លិខិតបញ្ជាក់ពីប្រព័ន្ធគ្រប់គ្រងអគ្គីភ័យ និងប្រព័ន្ធការពារ សន្តិសុខ សុវត្ថិភាព ចេញដោយ ក្រសួងមហាផ្ទៃ ឬ ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត
- ➢ អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំ
- ➢ វិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
- ➢ រូបថតរបស់អ្នកគ្រប់គ្រង (៤x៦)

# ឯកសារតម្រូវ

**៣. ឯកសារតម្រូវសម្រាប់អាជ្ញាបណ្ណភ្នាក់ងារទេសចរណ៍ និងការីទេសចរណ៍៖**

- លិខិតកក់ប្រាក់ធានាអាជីវកម្មពីធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា
- កិច្ចសន្យាអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងច្បាប់នានារបស់រដ្ឋ
- លក្ខន្តិកៈ (សម្រាប់ក្រុមហ៊ុន)
- អត្តសញ្ញាណប័ណ្ណ (ខ្មែរ) ឬលិខិតឆ្លងដែន (ជនបរទេស) របស់អ្នកស្នើសុំ
- លិខិតបញ្ជាក់ទីស្នាក់ការ ឬកិច្ចសន្យាជួលផ្ទះមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន
- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
- រូបថតរបស់អ្នកគ្រប់គ្រង (៤x៦)
- ប័ណ្ណពន្ធប៉ាតង់

# ឯកសារតម្រូវ

**សម្គាល់៖** ឯកសារតម្រូវមួយចំនួន គឺដូចគ្នានឹងឯកសារតម្រូវ សម្រាប់ការចុះបញ្ជីអាជីវកម្ម ។ ក្នុងន័យនេះ, ប្រសិនបើក្រុមហ៊ុន-សហគ្រាសរបស់លោកអ្នក ត្រូវបានចុះបញ្ជីអាជីវកម្ម តាមរយៈប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ឬហៅកាត់ថា Single Portal, លោកអ្នកពុំចាំបាច់ផ្តល់ឯកសារដដែលនោះទៀតទេ ។

# តារាងតម្លៃ

តារាងតម្លៃសេវា នៃប្រភេទអាជ្ញាបណ្ណខាងក្រោម៖

- អាជ្ញាបណ្ណសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍
- អាជ្ញាបណ្ណភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍
- អាជ្ញាបណ្ណភ្នាក់ងារទេសចរណ៍ និងការីទេសចរណ៍

# អាជ្ញាបណ្ណសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍

| ប្រភេទ | តម្លៃ |
|---|---|
| កន្លែងបោះជំរុំត្រឹម ១ ហិកតា | ៨០០,០០០ |
| កន្លែងបោះជំរុំលើសពី ១ ហិកតា | ១,៣០០,០០០ |
| ផ្ទះភ្ញៀវ(សេវាកម្មស្នាក់នៅទេសចរណ៍) ដែលត្រូវបង់ថ្លៃអាជ្ញាបណ្ណទៅតាមចំនួនបន្ទប់ | ១៥,០០០ ក្នុង ១បន្ទប់ |
| សណ្ឋាគារ ឬ សណ្ឋាគារអាផាតមិន ឬ សណ្ឋាគារស្វីត ឬប៊ីងហ្គាឡូ ឬម៉ូតែល ឬឡូដ៏ ដែលមានទំហំចាប់ពី ២១បន្ទប់ ដល់ ៣០បន្ទប់ | ៨០០,០០០ |
| សណ្ឋាគារ ឬ សណ្ឋាគារអាផាតមិន ឬ សណ្ឋាគារស្វីត ឬប៊ីងហ្គាឡូ ឬម៉ូតែល ឬឡូដ៏ ដែលមានទំហំចាប់ពី ៣១បន្ទប់ ដល់ ៦០បន្ទប់ | ១,១០០,០០០ |

# អាជ្ញាបណ្ណសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍

| ប្រភេទ | តម្លៃ |
|---|---|
| សណ្ឋាគារ ឬ សណ្ឋាគារអាផាតមិន ឬ សណ្ឋាគារស្វីត ឬបឹងហ្គាឡូ ឬម៉ូតែល ឬឡូដ៍ ដែលមានទំហំចាប់ពី ៦១បន្ទប់ ដល់ ១០០បន្ទប់ | ១,៣០០,០០០ |
| សណ្ឋាគារ ឬ សណ្ឋាគារអាផាតមិន ឬ សណ្ឋាគារស្វីត ឬបឹងហ្គាឡូ ឬម៉ូតែល ឬឡូដ៍ ដែលមានទំហំចាប់ពី ១០១បន្ទប់ ដល់ ១៥០បន្ទប់ | ២,០០០,០០០ |
| សណ្ឋាគារ ឬ សណ្ឋាគារអាផាតមិន ឬ សណ្ឋាគារស្វីត ឬបឹងហ្គាឡូ ឬម៉ូតែល ឬឡូដ៍ ដែលមានទំហំចាប់ពី ១៥១បន្ទប់ ដល់ ២០០បន្ទប់ | ២,៦០០,០០០ |
| សណ្ឋាគារ ឬ សណ្ឋាគារអាផាតមិន ឬ សណ្ឋាគារស្វីត ឬបឹងហ្គាឡូ ឬម៉ូតែល ឬឡូដ៍ ដែលមានទំហំចាប់ពី ២០១បន្ទប់ ដល់ ៣០០បន្ទប់ | ៣,៣០០,០០០ |
| សណ្ឋាគារ ឬ សណ្ឋាគារអាផាតមិន ឬ សណ្ឋាគារស្វីត ឬបឹងហ្គាឡូ ឬម៉ូតែល ឬឡូដ៍ ដែលមានទំហំចាប់ពី ៣០១បន្ទប់ ឡើងទៅ | ៤,០០០,០០០ |

# អាជ្ញាបណ្ណភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍

| ប្រភេទ | តម្លៃ |
|---|---|
| ភោជនីយដ្ឋាន-អាហារដ្ឋានទេសចរណ៍ចំណុះពី ១០១ ដល់ ២០០ នាក់ | ៨០០,០០០ |
| ភោជនីយដ្ឋាន-អាហារដ្ឋានទេសចរណ៍ចំណុះពី ២០១ ដល់ ៣០០ នាក់ | ១,៣០០,០០០ |
| ភោជនីយដ្ឋាន-អាហារដ្ឋានទេសចរណ៍ចំណុះពី ៣០១ នាក់ឡើងទៅ | ១,៦០០,០០០ |

# អាជ្ញាបណ្ណភ្នាក់ងារទេសចរណ៍ និងការីទេសចរណ៍

| ប្រភេទ | តម្លៃ |
|---|---|
| ទីភ្នាក់ងារទេសចរណ៍ | ១,២០០,០០០ |
| ការីទេសចរណ៍នាំភ្ញៀវកំសាន្តក្នុងកម្ពុជា | ៦០០,០០០ |
| ការីទេសចរណ៍នាំភ្ញៀវចូលក្នុងកម្ពុជា | ១,២០០,០០០ |
| ការីទេសចរណ៍នាំភ្ញៀវចេញក្រៅកម្ពុជា | ១,៤០០,០០០ |

# ទម្រង់នៃអាជ្ញាបណ្ណទេសចរណ៍



ក្រសួងទេសចរណ៍

លេខ: 20210724000001 ក.ទ.ច

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អាជ្ញាបណ្ណទេសចរណ៍

## TOURISM LICENSE

CAMBODIA

Kingdom of Wonder

feel the warmth

អនុញ្ញាតឱ្យលោក-លោកស្រី ............ សាន សូរិយ៉ា - SAN SORIYA

ស្ថិតនៅផ្ទះលេខ ............ 67 ផ្លូវ 12 ឃុំ~សង្កាត់ កំពេញ

ក្រុង-ស្រុក-ខណ្ឌ ............ ស្ទឹងហាវ ............ រាជធានី-ខេត្ត ............ ព្រះសីហនុ

ប្រកបអាជីវកម្ម ............ សណ្ឋាគារ

អាជីវកម្មឈ្មោះ ............ ក្រុមហ៊ុនតេស្តសាកល្បង

ចាប់ពីថ្ងៃទី ............ ២៤-០៧-២០២១ (24-07-2021) ............ ដល់ ............ ២៤-០៧-២០២២ (24-07-2022)

ថ្ងៃ ... សៅរ៍ ១៥ កើត ខែ ទុតិយាសាឍឆ្នាំ ... ឆ្លូវ ត្រីស័ក ... ព.ស ... ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ... ២៤ ខែ ... កក្កដា ឆ្នាំ ... ២០២១

ត.ប.រដ្ឋមន្ត្រី

អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍

បណ្ឌិត សោម សាមុត

# ព័ត៌មានផ្សេងៗ

- **គេហទំព័រ៖** https://tourismcambodia.org/ ឬ https://www.registrationservices.gov.kh/
- **លេខទូរស័ព្ទទំនាក់ទំនង៖** ០៨១ ៨៨៨ ២៩៦ ឬ ០៩២ ៥៩៣ ៥៧៨
- **អ៊ីម៉ែល៖** tourismlicense.camdx@gmail.com
- **អាសយដ្ឋាន៖** ដីឡូត៍លេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
- **ហ្វេសប៊ុក៖** https://www.facebook.com/cambodia.tourism.ministry

  ឬ https://www.facebook.com/Online.Business.Registration

# ២. សំណើសុំអាជ្ញាបណ្ណ ទេសចរណ៍



# ការចូលទៅក្នុងគេហទំព័រ




កម្មវិធីទូរស័ព្ទ CamDigiKey




គេហទំព័ររបស់អ្នកប្រើប្រាស់

# ការចូលទៅក្នុងគេហទំព័រ

ជាដំបូង អ្នកប្រើប្រាស់ចាំបាច់ត្រូវមានគណនី CamDigiKey នៅលើទូរស័ព្ទដៃជាមុនសិន។ ដើម្បីចូលប្រើប្រាស់ប្រព័ន្ធ សូមចុចលើប៊ូតុង **ទាញយក QR Code**។ បន្ទាប់មកគ្រាន់តែចូលទៅកាន់កម្មវិធី CamDigiKey នៅលើទូរស័ព្ទដៃ ដើម្បីស្កេន QR Code ដែលទទួលបាន រួចវាយលេខសម្ងាត់ ៦ ខ្ទង់របស់លោកអ្នកឱ្យបានត្រឹមត្រូវ នោះលោកអ្នកនឹងអាចចូលប្រើប្រាស់ប្រព័ន្ធបានដោយស្វ័យប្រវត្តិ។



# នៅក្នុងគេហទំព័រ

ខាងក្រោម ជាផ្ទាំងទំព័រដើមដែលបានបង្ហាញអំពីព័ត៌មាន និងស្ថានភាពរបស់អាជ្ញាបណ្ណ។




| លេខរៀង | Single ID | នាមករណ៍ក្រុមហ៊ុន (ខ្មែរ) | នាមករណ៍ក្រុមហ៊ុន (ឡាតាំង) | កាលបរិច្ឆេទស្នើសុំ | កាលបរិច្ឆេទសម្រេចចុងក្រោយ | ប្រភេទអាជ្ញាបណ្ណ |
|---|---|---|---|---|---|---|
| ១ | ១០០១០៣០ | វីធី ស៊ីសខម ឯ.ក | V&T SWISSCOM CO., LTD. | - | - | សណ្ឋាគារ ឬសេវាស្នាក់ |
| ២ | ១០០១០៣០ | វីធី ស៊ីសខម ឯ.ក | V&T SWISSCOM CO., LTD. | - | - | ទីភ្នាក់ងារទេសចរណ៍ |
| ៣ | ១០០១០៣០ | វីធី ស៊ីសខម ឯ.ក | V&T SWISSCOM CO., LTD. | - | - | - |

# ការបំពេញព័ត៌មាន

ខាងក្រោម ជាផ្ទាំងបំពេញព័ត៌មានលម្អិតរបស់អាជីវកម្ម។



# ការបំពេញព័ត៌មាន

ប្រសិនបើអាជីវកម្មធ្លាប់ចុះបញ្ជីតាមប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ឬហៅកាត់ថា Single Portal នោះអ្នកបំពេញអាចទាញយកព័ត៌មានក្រុមហ៊ុន និងទីតាំងដោយស្វ័យប្រវត្តិតាមរយៈលេខអត្តសញ្ញាណសហគ្រាស(Single ID) ដែលចុះពីក្រសួងពាណិជ្ជកម្ម។



# ការបំពេញព័ត៌មាន

❖ ផ្ទាំងបំពេញព័ត៌មានលំអិតរបស់ម្ចាស់អាជីវកម្ម

- ព័ត៌មានម្ចាស់អាជីវកម្ម
- អាសយដ្ឋាន



# ការបំពេញព័ត៌មាន

❖ ផ្ទាំងបំពេញព័ត៌មានលំអិតអំពីអាជ្ញាបណ្ណ

- ព័ត៌មានអំពីអាជ្ញាបណ្ណ



# ការបំពេញព័ត៌មាន

❖ ផ្ទាំងបំពេញឯកសារភ្ជាប់

- ឯកសារភ្ជាប់ដែលតម្រូវទៅតាមប្រភេទអាជ្ញាបណ្ណ
- បណ្ណត្រួតពិនិត្យ



# ការបំពេញព័ត៌មាន

❖ ផ្ទាំងបំពេញព័ត៌មានលំអិតរបស់បណ្ណត្រួតពិនិត្យ






# ការបំពេញព័ត៌មាន

❖ ផ្ទាំងផ្ទៀងផ្ទាត់ព័ត៌មានដែលបានបំពេញរួចរាល់



# ការទូទាត់បង់ប្រាក់

❖ ផ្ទាំងបង្ហាញព័ត៌មានតម្លៃអាជ្ញាបណ្ណ



# ការទូទាត់បង់ប្រាក់

❖ ផ្ទាំងបំពេញព័ត៌មានបង់ប្រាក់ និងបង់ប្រាក់ជោគជ័យ






# ការទាញយកអាជ្ញាបណ្ណ

❖ ទាញយកអាជ្ញាបណ្ណជាទម្រង់ឌីជីថលក្រោយពីទទួលបានការអនុម័ត



# ការទាញយកអាជ្ញាបណ្ណ

❖ គំរូអាជ្ញាបណ្ណក្រោយទាញយក


ក្រសួងទេសចរណ៍
លេខ: 20210724000001 ក.ទ.ច

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាបណ្ណទេសចរណ៍
TOURISM LICENSE

អនុញ្ញាតឱ្យលោក-លោកស្រី សាន សូរិយ៉ា - SAN SORIYA
ស្ថិតនៅផ្ទះលេខ 67 ផ្លូវ 12 ឃុំ-សង្កាត់ កំពេញ
ក្រុង-ស្រុក-ខណ្ឌ ស្ទឹងហាវ រាជធានី-ខេត្ត ព្រះសីហនុ
ប្រភេទអាជីវកម្ម សណ្ឋាគារ
អាជីវកម្មឈ្មោះ ក្រុមហ៊ុនតេស្តសាកល្បង
ចាប់ពីថ្ងៃទី ២៤-០៧-២០២១ (24-07-2021) ដល់ ២៤-០៧-២០២២ (24-07-2022)

ថ្ងៃ សៅរ៍ ១៥ កើត ខែ ទុតិយាសាឍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០២១
ត.ម. រដ្ឋមន្ត្រី
អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍
បណ្ឌិត ឆោម សាមុត

# សូមអរគុណ

